ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

**លេខ និង ឈ្មោះសំណុំរឿង : ៩០/១១-គ្រីនចិច**

**កាលបរិច្ឆេទនៃសេចក្តីបង្គាប់ : ថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១១**

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក: **អ៊ុក រី**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត: **លីវ សុវណ្ណា**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ: **ប៉ែន ប៊ុនឈា**

## ភាគីនៃវិវាទ

១- ភាគីនិយោជក

ឈ្មោះ : **ក្រុមហ៊ុន គ្រីន តិច អេកូ ផាក (ខេមបូឌា) ខូ អិលធីឌី**

អាសយដ្ឋាន : ភូមិព្រៃបឹង សង្កាត់កន្ទោក ខណ្ឌដង្កោ រាជធានីភ្នំពេញ

ទូរស័ព្ទ : ០១២ ៧៦៦ ៤២៣ ទូរសារ : គ្មាន

តំណាងភាគីនិយោជក :

១- លោក សេក សុវណ្ណ ប្រធានរដ្ឋបាល

២- លោក លី ឆេង ទីប្រឹក្សាក្រុមហ៊ុន

២- ភាគីកម្មករនិយោជិត

ឈ្មោះ : - **សព័ន្ធសហជីពយុវជនខ្មែរ**

- **សហជីពយុវជនខ្មែរ ក្រុមហ៊ុន គ្រីន ចិច**

អាសយដ្ឋាន : ភូមិព្រៃបឹង សង្កាត់កន្ទោក ខណ្ឌដង្កោ រាជធានីភ្នំពេញ

លេខទូរស័ព្ទ : ០៨៩ ៨១៨ ១៥២ ទូរសារ : គ្មាន

តំណាងកម្មករនិយោជិត:

១- លោក សែម សំអឿន មន្ត្រីសហព័ន្ធសហជីពយុវជនខ្មែរ

២- លោក សៀ សន មន្ត្រីសហព័ន្ធសហជីពយុវជនខ្មែរ

៣- លោក អៀង ឡាយសេង ប្រធានសហជីពយុវជនខ្មែរ ក្រុមហ៊ុន គ្រីន ធីច

៤- លោក ពៅ សួស្តី អនុប្រធានសហជីពយុវជនខ្មែរ ក្រុមហ៊ុន គ្រីន ធីច

៥- លោក អ៊ុត សាបិន លេខាសហជីពយុវជនខ្មែរ ក្រុមហ៊ុន គ្រីន ធីច

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- កម្មករនិយោជិតទាមទារសុំឱ្យក្រុមហ៊ុនផ្តល់សោហ៊ុយធ្វើដំណើរ និងការស្នាក់នៅចំនួន ៥ ដុល្លារ និងប្រាក់រង្វាន់ធ្វើការទៀងទាត់ចំនួន ១០ ដុល្លារ ក្នុងមួយខែ។ ដោយឡែកភាគីនិយោជកបញ្ជាក់ថា ក្រុមហ៊ុនពុំអាចផ្តល់ជូនតាមការទាមទារខាងលើបានទេ។

២- សុំឱ្យក្រុមហ៊ុនអនុញ្ញាតឱ្យថ្នាក់ដឹកនាំសហជីពយុវជនខ្មែរ ប្រចាំរោងចក្រ ប្រជុំពីរម៉ោងក្នុងមួយសប្តាហ៍ជារៀងរាល់ថ្ងៃសៅរ៍។ ដោយឡែកភាគីនិយោជកបញ្ជាក់ថា ក្រុមហ៊ុនពុំអាចផ្តល់ជូនបានទេ ប៉ុន្តែប្រតិភូបុគ្គលិកក្រុមហ៊ុន និងអនុញ្ញាតជូន។

៣- កម្មករនិយោជិតសុំឱ្យក្រុមហ៊ុនកាត់ប្រាក់រង្វាន់ធ្វើការទៀងទាត់ ដូចខាងក្រោម:

- ឈប់ឥតច្បាប់ចំនួនមួយថ្ងៃដាច់ចំនួន ៣ ដុល្លារ
- ឈប់ឥតច្បាប់ចំនួនពីរថ្ងៃដាច់ចំនួន ៦ ដុល្លារ
- ឈប់ឥតច្បាប់ចំនួនបីថ្ងៃដាច់ទាំងអស់។

ដោយឡែកភាគីនិយោជកបញ្ជាក់ថា ចំពោះប្រាក់រង្វាន់ធ្វើការទៀងទាត់ ក្រុមហ៊ុនអនុវត្តទៅតាមសេចក្តីជូនដំណឹងរបស់ក្រសួងលេខ ០៤១/១១ ក.ប/ស.ជ.ណ ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១១។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ(ខ)(មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៣៦ កប/ប្រក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១១ (អាណត្តិទី៩)។

THE ARBITRATION COUNCIL

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជាលេខ ៨១៤ ក.ប/អក/វ.ក ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១១ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១១។

**សវនាការ និង សន្ទេបនីតិវិធី**

**ទីកន្លែងសវនាការ :** ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ :** ថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០១១ (វេលាម៉ោង ០៨:៣០ នាទី ព្រឹក ) ។

**បញ្ហានៃនីតិវិធី :**

នៅថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១១ នាយកដ្ឋានវិវាទការងារ បានទទួលពាក្យបណ្តឹងរបស់សហព័ន្ធសហជីពយុវជនខ្មែរ លេខ ១៣៤ សសយខ ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១១ ស្តីពីការទាមទារឱ្យក្រុមហ៊ុនកែលំអលក្ខខណ្ឌការងារឱ្យបានល្អប្រសើរ ។

បន្ទាប់ពីបានទទួលពាក្យបណ្តឹងនេះមក នាយកដ្ឋានវិវាទការងារ បានចាត់មន្ត្រីជំនាញធ្វើការដោះស្រាយវិវាទការងាររួមនេះ និងផ្សះផ្សានៅថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១១ ដោយទទួលបានលទ្ធផលសះជានឹងគ្នាចំនួន ១០ ចំណុច និងមិនសះជាចំនួន ០៣ ចំណុច លើការទាមទារចំនួន ១៣ ចំណុច ។ ចំណុចវិវាទដែលមិនសះជានឹងគ្នាចំនួន ០៣ ចំណុចនេះ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១១ តាមរយៈរបាយការណ៍ដោះស្រាយវិវាទការងាររួមមិនសះជាលេខ ៨១៥ កប/អក/វក ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ ២០១១។

បន្ទាប់ពីបានទទួលសំណុំរឿងនេះរួចមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល បានកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន ០៣ ចំណុចនេះ នៅថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១១ វេលាម៉ោង ០៨:៣០ នាទី ព្រឹក ។

ភាគីទាំងពីរមានវត្តមាននៅថ្ងៃសវនាការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមសួររកនូវអង្គហេតុផ្សេងៗ ដែលទាក់ទងទៅនឹងវិវាទនេះ និងបានធ្វើការផ្សះផ្សាលើចំណុចមិនសះជាចំនួន ០៣ ចំណុចនេះបន្ថែមទៀត ដោយទទួលបានលទ្ធផលសះជានឹងគ្នា ដោយភាគីកម្មករនិយោជិតបានដក ចំណុចវិវាទទី២ និចំណុចវិវាទទី៣ ចេញពីការទាមទារក្នុងសំណុំរឿងនេះ ។ ដោយឡែក ចំណុចវិវាទទី១ ពាក់ព័ន្ធនឹងការទាមទារទាក់ទងប្រាក់រង្វាន់ការងារឡើងទាត់ចំនួន ១០ ដុល្លារអាមេរិក ក្នុងមួយខែ ភាគីកម្មករនិយោជិត ក៏បានដកចេញពីការទាមទារក្នុងសំណុំរឿងនេះដែរ ។

ហេតុនេះ ចំណុចមិនសះជាក្នុងចំណុចវិវាទទី១ ដែលនៅសល់ ទាក់ទងនឹងការទាមទារអំពីប្រាក់សោហ៊ុយធ្វើដំណើរ និងថ្លៃឈ្នួលផ្ទះស្នាក់នៅចំនួន ៥ ដុល្លារអាមេរិកក្នុងមួយខែ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណា និងដោះស្រាយ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម:

**ភស្តុតាង**

សាក្សី និងអ្នកជំនាញក្រៅពីភាគី : គ្មាន

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

**ក- ឯកសារបានទទួលពីភាគីនិយោជក :**

១- លិខិតផ្ទេរសិទ្ធិរបស់នាយកក្រុមហ៊ុន គ្រីន តិច អេកូ ផាក (ខេមបូឌា) ខូ អិលធីឌី ផ្ទេរសិទ្ធិជូនលោក លី ឆេង និងលោក សេក សុវណ្ណ ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០១១។

២- សារណាសង្ខេបនៃវិវាទការងាររបស់ក្រុមហ៊ុន គ្រីន តិច អេកូ ផាក (ខេមបូឌា) ខូ អិលធីឌី ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១១។

៣- លក្ខន្តិកៈរបស់ក្រុមហ៊ុន គ្រីន តិច អេកូ ផាក (ខេមបូឌា) ខូ អិលធីឌី ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០០៩។

៤- បទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន គ្រីន តិច អេកូ ផាក (ខេមបូឌា) ខូ អិលធីឌី ចុះបញ្ជិកាលេខ ៥៧៥១ ក.ប.ក.ណ ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១០។

៥- វិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន គ្រីន តិច អេកូ ផាក (ខេមបូឌា) ខូ អិលធីឌី លេខ ៤៤១០ ពណ.ចបព ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០០៩។

៦- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមរបស់ក្រុមហ៊ុន គ្រីន តិច ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១១។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត :**

១- លិខិតរបស់ប្រធាននាយកដ្ឋានវិវាទការងារ ជំរាបមក លោកប្រធានសហជីពយុវជនខ្មែរក្រុមហ៊ុន គ្រីន ចិច ស្តីពីការស្នើសុំទទួលស្គាល់ថ្នាក់ដឹកនាំសហជីពថ្មី លេខ ៨៤៦ ក.ប./អក/វក ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០។

២- វិញ្ញាបនប័ត្រចុះបញ្ជិកាសហជីពយុវជនខ្មែរក្រុមហ៊ុន គ្រីន ចិច លេខ ១៩២១ កប/វក. ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១១។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ:**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន គ្រីន ចិច លេខ ៨១៤ កប/អក/វក ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១១។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមរបស់ក្រុមហ៊ុន គ្រីន ធិច ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ ២០១១។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ៥៣៨ កប/អក/វក/លកអ. ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១១។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ៥៣៩ កប/អក/វក/លកអ. ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១១។

៣- ការព្រមព្រៀងយកសេចក្តីបង្គាប់ជាប់កាតព្វកិច្ច ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១១។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និង ភាគីនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

**ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ៖**

- ក្រុមហ៊ុន គ្រីន ធិច បានបើកដំណើការនៅ ឆ្នាំ២០០៩ ជាក្រុមហ៊ុនផលិតស្បោងផ្លាសស្ទិច។ ប៉ុន្តែ ទើបនឹងដំណើរការផលិតកម្មបានល្អនៅក្នុងអំឡុង ៦ ខែចុងក្រោយ ដើមឆ្នាំ២០១១ នេះ។ បច្ចុប្បន្ន ក្រុមហ៊ុនមានជួលកម្មករនិយោជិតសរុបប្រហែល ២០០ នាក់។
- សហជីពយុវជនខ្មែរប្រចាំក្រុមហ៊ុន គ្រីន ធិច ដែលជាដើមបណ្តឹងក្នុងរឿងនេះ មានសមាជិកប្រហែល ៩២ នាក់។ សហជីពនេះ ពុំទាន់មានបញ្ជិកាបញ្ជាក់ពីភាពជាតំណាងបំផុតទេ។

**ចំណុចវិវាទទី១៖ កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនផ្តល់សោហ៊ុយធ្វើដំណើរ និងថ្លៃឈ្នួលផ្ទះស្នាក់នៅចំនួន ៥ ដុល្លារអាមេរិក ក្នុងមួយខែ ដល់កម្មករនិយោជិត**

- ការអនុវត្តនៅក្នុងក្រុមហ៊ុន គឺក្រុមហ៊ុនមិនដែលផ្តល់សោហ៊ុយធ្វើដំណើរ និងថ្លៃឈ្នួលផ្ទះស្នាក់នៅចំនួន ៥ ដុល្លារអាមេរិកក្នុងមួយខែដល់កម្មករនិយោជិត ទាំងកម្មករនិយោជិត ដែលធ្វើការវេណថ្ងៃ និង កម្មករនិយោជិត ដែលធ្វើការវេណយប់។
- ភាគីក្រុមហ៊ុន និងកម្មករនិយោជិត មិនដែលមានកិច្ចសន្យា ឬកិច្ចព្រមព្រៀង ឬអនុស្សរណៈរួម ដែលចែងពីការផ្តល់សោហ៊ុយធ្វើដំណើរ និងថ្លៃឈ្នួលផ្ទះស្នាក់នៅចំនួន ៥ ដុល្លារអាមេរិក ក្នុងមួយខែ ដល់កម្មករនិយោជិតទេ។

THE ARBITRATION COUNCIL

- មានកម្មករនិយោជិតពី៦០% ទៅ ៧០%នៃកម្មករនិយោជិតទាំងអស់ ធ្វើដំណើរពីផ្ទះរបស់ខ្លួន មកធ្វើការនៅក្រុមហ៊ុនដោយជិះឡានឈ្នួលដាក់ខែ ហើយកម្មករនិយោជិតពី ៣០% ទៅ៤០% នៃកម្មករនិយោជិតទាំងអស់ស្នាក់នៅផ្ទះជួល នៅក្បែរក្រុមហ៊ុន។
- កម្មករនិយោជិតបញ្ជាក់ថា មូលហេតុដែលពួកគេទាមទារលើចំណុចនេះ ដោយសារថា ផ្ទះកម្មករនិយោជិតនៅឆ្ងាយពីក្រុមហ៊ុន ដែលត្រូវចំណាយប្រាក់ធ្វើដំណើរ និងបង់ថ្លៃជួលផ្ទះច្រើន ព្រោះឥឡូវនេះថ្លៃឡានឈ្នួល និងថ្លៃជួលផ្ទះឡើងថ្លៃ និងម្យ៉ាងទៀតនៅរោងចក្រគេផ្សេងៗផ្តល់នូវប្រាក់នេះដែរ។
- ភាគីក្រុមហ៊ុនបានបញ្ជាក់ថា និយោជកមិនអាចផ្តល់ជូនតាមការទាមទារទេ ព្រោះមិនមានច្បាប់តម្រូវឱ្យក្រុមហ៊ុនផ្តល់ប្រាក់សោហ៊ុយធ្វើដំណើរ និងថ្លៃឈ្នួលផ្ទះស្នាក់នៅចំនួន ៥ ដុល្លារអាមេរិក ក្នុងមួយខែដល់កម្មករនិយោជិតទេ។ ម្យ៉ាងទៀត ស្ថានភាពសេដ្ឋកិច្ចរបស់ក្រុមហ៊ុនមិនទាន់បានប្រសើរទេ ពោលគឺមិនទាន់មានចំណេញច្រើនទេ ហើយនៅខ្វះខាតហិរញ្ញវត្ថុនៅឡើយ។

## **ហេតុផលនៃសេចក្តីសម្រេច:**

**ចំណុចវិវាទទី១: កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនផ្តល់សោហ៊ុយធ្វើដំណើរ និងថ្លៃឈ្នួលផ្ទះស្នាក់នៅចំនួន ៥ ដុល្លារអាមេរិក ក្នុងមួយខែ ដល់កម្មករនិយោជិត**

ភាគីកម្មករនិយោជិតបញ្ជាក់ការទាមទារខាងលើនេះ ដោយមូលហេតុថា ថ្លៃឈ្នួលឡាន និងថ្លៃឈ្នួលផ្ទះរបស់កម្មករនិយោជិតឡើងថ្លៃ និងរោងចក្រគេផ្សេងៗទៀតបានផ្តល់ប្រាក់នេះដល់កម្មករនិយោជិតរបស់គេ។ ប៉ុន្តែក្រុមហ៊ុនមិនព្រមតាមការទាមទារទេ ដោយផ្អែកលើហេតុផលថា មិនមានច្បាប់តម្រូវ និងមិនមានលទ្ធភាពផ្តល់ប្រាក់នេះទេ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាករណីនេះ ដូចខាងក្រោម:

យោងតាមអង្គហេតុ ការទាមទារទាក់ទងនឹងសោហ៊ុយធ្វើដំណើរ និងថ្លៃឈ្នួលផ្ទះស្នាក់នៅចំនួន ៥ ដុល្លារអាមេរិកក្នុងមួយខែ ដល់កម្មករនិយោជិតនេះ មិនមានចែងក្នុងច្បាប់ កិច្ចព្រមព្រៀង ឬអនុសញ្ញារួមណាមួយរវាងកម្មករនិយោជិត និងនិយោជកទេ។ ការទាមទារនេះ ជាការទាមទារអំពីផលប្រយោជន៍ ដែលប្រសើរជាងច្បាប់កំណត់។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការទាមទារនេះ ជាវិវាទអំពីផលប្រយោជន៍។

ជាទូទៅ ចំពោះវិវាទទាក់ទងនឹងផលប្រយោជន៍ ក្រុមប្រឹក្សាអាជ្ញាកណ្តាលតែងតែពិចារណាលើភាពជាតំណាងបំផុតរបស់សហជីព ដែលជាភាគីវិវាទ។ នៅក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបដិសេធពិចារណាវិវាទអំពីផលប្រយោជន៍ ប្រសិនបើសហជីពដែលនាំវិវាទការងារនោះមក ជាសហជីពដែលមិនមានភាពតំណាងបំផុតនៅក្នុងរោងចក្រ។ (*សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ៨១/០៤-អេរ៉ាគ្រីន ហេតុផលចំណុចវិវាទទី៤, លេខ ០៩/០៥-គីន តាយ ហេតុផលចំណុចវិវាទទី២, លេខ ១៣៥/០៧-វិលស៊ិន ហេតុផលចំណុចវិវាទទី១, លេខ ១៤/០៨-ហ្វ៊ិក ស៊ូ ហេតុផលចំណុចវិវាទទី៣, លេខ ៨២/០៩ ហេតុផល ចំណុចវិវាទទី២ លេខ*

*០២/១១-ពូ យៀន ហេតុផលចំណុចវិវាទទី២ និងលេខ ៦៦/១១-អ៊ិន ហាន ស៊ុង ហេតុផលចំណុចវិវាទទី១)* ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាពជាតំណាងបំផុតរបស់សហជីពនេះ ផ្តល់គុណវុឌ្ឍិផ្នែកផ្លូវច្បាប់ក្នុងការចរចាបង្កើតអនុសញ្ញារួមក្នុងក្រុមហ៊ុន និងមានសិទ្ធិស្របច្បាប់ក្នុងការនាំសំណុំរឿងវិវាទអំពីប្រយោជន៍មកឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការដោះស្រាយ ។

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ស្របនឹងការបកស្រាយ របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗខាងលើដែរ ។ នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា សហជីពយុវជនខ្មែរប្រចាំក្រុមហ៊ុន គ្រីន ចិចនេះ មិនទាន់មានបញ្ជិកាភាពជាតំណាងបំផុត ដូចមានចែងក្នុងមាត្រា២៧៧ នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ចែងថា "*សហជីពត្រូវចុះបញ្ជិកា និងត្រូវបំពេញតាមលក្ខខណ្ឌផ្សេងៗទៀត ដែលមានចែងក្នុងមាត្រានេះ* " ។

ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា សហជីពយុវជនខ្មែរប្រចាំក្រុមហ៊ុន គ្រីន ចិច មិនទាន់មានសិទ្ធិស្របតាមផ្លូវច្បាប់ក្នុងការនាំវិវាទពីផលប្រយោជន៍មកឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការដោះស្រាយទេ ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បដិសេធពិចារណាការទាមទាររបស់កម្មករនិយោជិត ឱ្យក្រុមហ៊ុនផ្តល់សោហ៊ុយធ្វើដំណើរ និងថ្លៃឈ្នួលផ្ទះស្នាក់នៅចំនួន ៥ ដុល្លារអាមេរិក ក្នុងមួយខែ ដល់កម្មករនិយោជិត ។

យោងតាមអង្គហេតុ ដែលបានរកឃើញ អង្គច្បាប់ និងហេតុផលដូចបានពន្យល់ខាងដើម ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច ដូចតទៅនេះ:

## សម្រេច និង បង្គាប់

**ចំណុចវិវាទទី ១ :** បដិសេធពិចារណាការទាមទាររបស់កម្មករនិយោជិត ឱ្យក្រុមហ៊ុនផ្តល់សោហ៊ុយធ្វើដំណើរ និងថ្លៃឈ្នួលផ្ទះស្នាក់នៅចំនួន ៥ ដុល្លារអាមេរិក ក្នុងមួយខែ ដល់កម្មករនិយោជិត ។

**ប្រភេទនៃសេចក្តីបង្គាប់ : សេចក្តីបង្គាប់ជាប់កាតព្វកិច្ច**

*សេចក្តីបង្គាប់នេះនឹងក្លាយជាស្ថាពរភ្លាម ហើយអនុវត្តចំពោះភាគីតែម្តង បន្ទាប់ពីសេចក្តីបង្គាប់នេះចេញទៅ ដោយភាគីទាំងពីរបានយល់ព្រមជ្រើសរើសយកសេចក្តីបង្គាប់នេះ នៅថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១១ ។*

THE ARBITRATION COUNCIL

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្ដាល**

**អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីនិយោជក :**

ឈ្មោះ : **អ៊ុក រី**

ហត្ថលេខា: ------------------------------

**អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីកម្មករនិយោជិត :**

ឈ្មោះ : **លឹម សុវណ្ណា**

ហត្ថលេខា: ------------------------------

**ប្រធានក្រុមអាជ្ញាកណ្ដាល :**

ឈ្មោះ : **ម៉ែន ម៉ុនឈរា**

ហត្ថលេខា: ------------------------------